ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៥៧៣ ព.ណ.ត.ស.ម

ថ្ងៃ ចន្ទ ៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ៦ ឆ្នាំ ២០២១

## **ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ភើណូដ រីខាដ (ខេមបូដ) ឯ.ក**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្រាម៉ាក **"JACOB'S CREEK"** របស់ក្រុមហ៊ុន **ភើណូដ រីខាដ (ខេមបូដ) ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- លិខិតស្នើសុំរបស់ក្រុមហ៊ុន **ភើណូដ រីខាដ (ខេមបូដ) ឯ.ក** ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០២១
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Pernod Ricard Winemakers Pty Ltd. ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២១
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៧៥៨៤/០៣ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្រាពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **ភើណូដ រីខាដ (ខេមបូដ) ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Pernod Ricard Winemakers Pty Ltd. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និង ចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃ ២៦ ខែសីហា ឆ្នាំ ២០២២ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Pernod Ricard Winemakers Pty Ltd. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា និងត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក_ប្រជា**

*<u>ចម្លងជូន:</u>*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ- កាលប្បវត្តិ*